**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈ**

ជាបឋម ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវអំណរព្រះមហាករុណាធិគុណ និង កតញ្ញូកតវេទិតាដ៏ជ្រាលជ្រៅបំផុត ថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងដែលព្រះអង្គទ្រង់ព្រះរាជហឫទ័យប្រោស ព្រះរាជទានគោរមងារចំពោះទូលព្រះបង្គំជាខ្ញុំជា **សម្តេចពិជ័យសេនា ទៀ បាញ់** ។

ជាកិច្ចតបស្នងចំពោះព្រះមហាករុណាធិគុណដ៏វិសេសវិសាលថ្លៃថ្លា ដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូងបាន សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគោរមងារដល់ទូលព្រះបង្គំ ជា សម្តេចពិជ័យសេនា ទៀ បាញ់ ទូលព្រះបង្គំជាខ្ញុំ នឹងខិតខំយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីដឹកនាំវិស័យការពារជាតិអោយបានត្រឹមត្រូវបម្រើប្រទេសជាតិ និងប្រជាជន ទូទាំងប្រទេសអោយរីកចម្រើន ស្របតាមបាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ។

ជាថ្មីម្តងទៀត ទូលព្រះបង្គំជាខ្ញុំសូមលំឱនកាយលើកហត្ថទាំងទ្វេប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រៃ វត្ថុសក្តិសិទ្ធិលើលោក និងទេវតារក្សាព្រះមហាស្វេតច្ឆត្រ សូមតាមជួយបីបាច់ប្រោះព្រំព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានប្រកបដោយព្រះកាយពលមាំមួន ព្រះរាជសុខភាពល្អបរិបូរណ៍ ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរដើម្បី ព្រះអង្គគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសុខដមរមនារបស់មាតុភូមិកម្ពុជាតរៀងទៅ ។

សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាទីសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវភក្តីភាព និងការគោរពដ៏ខ្ពង់ខ្ពស់ បំផុតពីទូលព្រះបង្គំជាខ្ញុំ ។

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៧*



**សម្តេចពិជ័យសេនា ទៀ បាញ់**